*គុណតម្លៃ*

*ការប្តេជ្ញាចិត្ត តម្លាភាព ភក្ដីភាព សុចរិត និង ភាពជាអ្នកបំរើ*

*ទស្សនៈវិស័យ*

*ប្រជាពលរដ្ឋមានទឹកប្រើប្រាស់សុខភាពអនាម័យ សេចក្តី និងបរិស្ថានល្អដើម្បីអោយជីវិតបានប្រសើរឡើង។*

# ការពិពណ៌នាការងារ

***បេសកកម្ម:*** *លើកកម្ពស់គុណភាពទឹក អនាម័យ សុខភាព និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងបណ្តាលសហគមន៍ គោលដៅដោយ ប្រើបច្ចេកវិទ្យា និងការអប់រំសមស្រប។*

## ១. ការសង្ខេបពីមុខតំណែង

| **មុខតំនែងនៃការងារ** | បុគ្គលិកស្ម័គ្រចិត្តផ្នែកតំឡើងចម្រោះទឹក។ |
|---|---|
| **ទីកន្លែង** | **ខេត្តស្វាយរៀង** |
| **ខ្សែរយៈ និង បណ្តាញរាយការណ៍** | • អ្នកសំខាន់ដែលត្រូវរាយការណ៍ជូនគឺ ប្រធានក្រុមផ្នែកបច្ចេកទេសចម្រោះទឹក។<br>• ការទំនាក់ទំនងផ្សេងទៀតគឺជាមួយគ្រួសារអ្នកទទួលផលក្នុង សហគមន៍ និងអ្នកទទួលផលផ្សេងទៀតដែលចូលរួមក្នុងកម្មវិធី ចម្រោះទឹក តាមរយៈ ការផ្តល់ពលកម្ម និងចូលរួមក្នុងការអប់រំផ្សព្វផ្សាយ ផ្នែកសុខភាព-អនាម័យ។<br>• ការទំនាក់ទំនងផ្សេងទៀតគឺជាមួយ ប្រធានភូមិ, ក្រុមប្រឹក្សាឃុំ, គណកម្មាធិការអភិវឌ្ឍន៍ភូមិ ។ |
| **គោលបំណងនៃមុខតំណែង** | • ធ្វើការជាមួយគំរោងដែលមានក្នុងសហគមន៍ ដើម្បីអោយពួកគេទទួលបាននូវទឹកប្រើប្រាស់ តាមការ រៀបចំតំឡើង ចម្រោះ និង ការអប់រំពីការប្រើប្រាស់ ធុងចម្រោះខ្សាច់ ។តាមដានចំពោះទឹកស្អាតបានដំឡើងរួចអប់រំ កែលំអនិងជំរុញលើកទឹកចិត្តអោយមាននិរន្ត ភាពក្នុងការប្រើប្រាស់ចម្រោះទឹកស្អាត។<br>• ថតរូប គ្រួសារដែលទទួលបានធុងចម្រោះ។<br>• ធ្វើកំណត់ត្រាចំនួនធុងចម្រោះដែលផ្តល់អោយដល់គ្រួសារជាក្រុមគោលដៅក្នុង GPS និង ប្រព័ន្ធទិន្នន័យ។ |
| **ការប្រឈមមុខនឹងមុខតំណែងនេះគឺ** | • រៀបចំគំរោងការដំឡើងធុងចម្រោះក្នុងសហគមន៍។<br>• គ្រួសារទទួលផលទាំងអស់និងអ្នកស្ម័គ្រចិត្តទទួលបានការយល់ដឹង អំពីការប្រើប្រាស់ និងតំហែទាំធុងចម្រោះបានល្អ។<br>• គ្រួសារដែលរស់នៅក្នុងសហគមន៍ ទទួលបានទឹកស្អាតប្រើប្រាស់។ |

## ២. ភារកិច្ចសំខាន់ៗ

| **ការទទួលខុសត្រូវច្បាស់លាស់** | **សកម្មភាពការងារជាក់លាក់** |
|---|---|
| **ការអភិវឌ្ឍន៍ និងការអប់រំ** | • រៀបចំតំឡើង ធុងចម្រោះអោយបានត្រឹមត្រូវ ដោយមានការចូលរួមពីគ្រួសារដែលទទួលផល។<br>• ជួយផ្តល់ការបង្រៀនដល់គ្រួសារអោយយល់អំពីគុណភាពល្អរបស់ធុងចម្រោះ ។ |

| | |
|---|---|
| | • ពន្យល់ដល់គ្រួសារទទួលផលអំពីដំការនៃការថែរក្សាធុងចំពោះអោយបានត្រឹមត្រូវនិងបំផុសស្មារតីម្ចាស់ការ។ |
| **ផ្គត់ផ្គង់ការគ្រប់គ្រង** | • ជួយដល់តំណាងអង្គការស្អាតកម្ពុជា ផ្នែកកិច្ចការរដ្ឋបាល ក្នុងការរៀបចំការកត់ត្រា ចំនួនធុងចម្រោះ ដែលតំឡើង ហើយ និង បញ្ចូលទៅក្នុង ប្រព័ន្ធ GPS និង ប្រព័ន្ធទិន្នន័យ ធ្វើការ បាន់ប្រមាណ ដោយផ្ទាល់ម៉ាត់អំពីការប្រើប្រាស់ ធុងចម្រោះដល់តំណាងអង្គការស្អាតកម្ពុជា។<br>• ថតរូបភាពសកម្មភាពកំពុងតំឡើងធុងចម្រោះដោយមានគ្រួសារទទួលផលចូលរួម។<br>• បំពេញការងារផ្សេងៗ ទៀតទៅតាមតំរូវការ របស់ប្រធានប្រចាំខេត្ត ស្នើសុំ ។ |
| **អប់រំសហគមន៍ និង ទំនាក់ទំនង** | • ជួយ ជំរុញ និង លើកទឹកចិត្តដល់ គ្រួសារដែលទទួលផល<br>• ជួយបង្រៀន និង ណែនាំពីការ ប្រើប្រាស់ ធុងចម្រោះដល់ សហគមន៍។ |
| **ការងារផ្សេងៗទៀត** | • ជួយដល់ការងារផ្សេងៗទៀតតាមតំរូវការ របស់ ប្រធានប្រចាំខេត្ត។ |

៣. លក្ខណៈសម្បត្តិត្រូវការ

| | <u>**សំខាន់ត្រូវតែមាន**</u> |
|---|---|
| **បទពិសោធន៏** | • បទពិសោធន៍ក្នុងការងារសហគមន៍ ឬការតំឡើង ចម្រោះ។<br>• បើកបររថយន្តបានកាន់តែប្រសើរ។ |
| **ការសិក្សាអប់រំ និង វគ្គបណ្ដុះបណ្ដាល** | បញ្ចប់ វិទ្យាល័យ ។ |
| **ជំនាញ** | • ជំនាញ បច្ចេកទេស<br>• មានសមត្ថភាព និងជំនាញក្នុងការ ចំឡើងធុងចម្រោះទៅគំរូរបស់កម្មវិធី។<br>• ធ្វើការងារ ដោយឯករាជម្ចាស់ការ និង បង្ហាញ ពីនំគិតថ្មីៗ ក្នុងដំណើការតំឡើងធុងចម្រោះ។<br>• មាន លទ្ធភាពក្នុងការ ណែនាំអំពីការលំហូទឹក ពីឡើងធុងចម្រោះ។<br>• មាន លទ្ធភាពក្នុងកំណត់មុខនាទី នៃ ដំណើការ និង មុខងារនៃធុងចម្រោះនៅពេលមានបញ្ហា។<br>• ជំនាញអភិវឌ្ឍន៍<br>• អាចធ្វើការណែនាំ, ពន្យល់ និង ការថែទាំ ធុងចម្រោះដល់អ្នកប្រើប្រាស់។ |
| **គុណសម្បត្តិផ្ទាល់ខ្លួន** | • ប្រកាន់ខ្ជាប់នូវតំលៃ និង បេសកកម្មរបស់ ស្អាត កម្ពុជា។<br>• សីលធម៌ការងារជាអាជីព។<br>• មានតម្លាភាពក្នុងការងារ និងហិរញ្ញវត្ថុ។<br>• មានបំណងធ្វើការក្នុងសហគមន៍។<br>• មានភាពបត់បែន។<br>• មានភាពប្រែប្រួលទៅនឹងស្ថានការណ៍។<br>• ប្រឹងប្រែងធ្វើការងារ។ |